# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ...០៣៣/១៩...ក.ប/ស.ជ.ណ.រ.ប.ប

ថ្ងៃអង្គារ ១២កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៩

## សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បេក្ខជនទាំងអស់ឱ្យបានជ្រាបថា **លទ្ធផលជាប់ជាស្ថាពរ និងជាប់បម្រុង នៃការប្រឡងជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌថ្មីកាលពីថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៩ នៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ នឹងបិទប្រកាសនៅទីស្តីការក្រសួង និងវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ នាថ្ងៃអង្គារ ១២កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៩:០០ នាទីយប់។**

ដោយឡែកដើម្បីឱ្យមានតម្លាភាពចំពោះបេក្ខជន ដែលបានប្រឡងជាប់ជាស្ថាពរនៅទីស្តីការក្រសួង (ថ្នាក់កណ្តាល) ចំនួន **០៧នាក់** ក្រសួងនឹងធ្វើការរៀបចំបែងចែកប៉ុស្តិ៍ និងជ្រើសរើសកន្លែងបម្រើការងាររបស់មន្ត្រីនីមួយៗ ដោយទុកឱកាសឱ្យអ្នកដែលមានចំណាត់ថ្នាក់ខ្ពស់និងថ្នាក់បន្តបន្ទាប់ មានសិទ្ធិជ្រើសរើសប៉ុស្តិ៍ (អង្គភាពដែលខ្លួនចង់ទៅបម្រើការងារ) រៀងៗខ្លួន។ ដូចនេះសូមបេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរទាំងអស់ (ទីស្តីការក្រសួង និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត) ត្រូវចូលរួមប្រជុំស្តាប់ការណែនាំ និងបំពេញឯកសារផ្សេងៗជាមួយនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក **នាថ្ងៃចន្ទ ៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ០៩:០០ នាទីព្រឹក នៅសាលប្រជុំ D ទីស្តីការក្រសួង។**

❖ **បញ្ជាក់៖ ចំពោះបេក្ខជនដែលអវត្តមាន ឬមិនបានចូលរួមតាមការអញ្ជើញនេះ ក្រសួងចាត់ទុកថាឯកភាពតាមការចាត់តាំងរបស់ក្រសួង ដោយមិនអាចតវ៉ាឬស្នើសុំផ្លាស់ប្តូរនៅពេលក្រោយបានឡើយ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម បេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ និងជា**

**អនុប្រធានគណៈកម្មការរៀបចំការប្រឡង**

**ហេង សួរ**

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង:**

- លោក គួយ គឿន ០៧៧ ៥១៨ ៥១១
- លោក ងួន ឆេង ០១២ ៧៣៣ ៤១១
- លោកស្រី ឡាយ ម៉ារីណា ០៩៨ ៩៩០ ០៣៤